# ស្នាដៃនិពន្ធប៉ិនប្រសប់

ដោយ លោក នភ ហង្ស ផលា

ភាសិតបុរាណមួយឃ្លាបានចែងថា "**ចេះដប់មិនស្មើប្រសប់មួយ**", ជាកត្តាបង្ហាញនូវតម្លៃដ៏ខ្ពង់ខ្ពស់នៃការប៉ិនប្រសប់របស់ខ្មែរ ។ ភាពប៉ិនប្រសប់នេះគឺជាមូលដ្ឋានឫសគល់ដ៏ជ្រៅនៃមោទនភាពជាតិខ្មែរ តាំងពីបុរេកាលរហូតមកដល់បច្ចុប្បន្ន តួយ៉ាងដូចជាស្នាដៃទាំងឡាយរបស់បុព្វបុរសយើងដែលបានបន្សល់នូវខ្លឹមសិល្បៈនិងគំនិតរចនាបថយ៉ាងប្រសិទ្ធ តាមរយៈសំណង់ប្រាង្គប្រាសាទល្បីៗ ភ្លេង របាំ ចម្រៀង ព្រមទាំងអត្ថបទអក្សរសិល្ប៍ដ៏ល្អប្រសើរជាច្រើនរាប់មិនអស់ ។ ថ្វីបើស្នាដៃទាំងឡាយមានអាយុរាប់សតវត្សទៅហើយក្តី ក៏សង្គមជាតិខ្មែរនៅតែអាចត្រងយកគុណប្រយោជន៍យ៉ាងមហិមាពីស្នាដៃដ៏វិចិត្រទាំងឡាយ នៅគ្រាបច្ចុប្បន្ននេះនៅឡើយ ដូចជាការទាញយកនូវផលប្រយោជន៍ពីទេសចរណ៍និងអ្នកស្រាវជ្រាវសកល ដោយសារតម្លៃដ៏ឧត្តមនៃសិល្បៈសូនរូបនិងចម្លាក់ថ្មតាមប្រាង្គប្រាសាទនានា តាំងពីជំនាន់មុនសម័យអង្គរ អំពីការបង្ហាញនូវសិល្បៈឆ្លាក់ឈើ សិល្បៈត្បាញសូត្រ សិល្បៈនិពន្ធសាច់ភ្លេង ទំនុក ច្រៀង និង សិល្បៈរចនារបាំ ទាំងបុរាណនិងប្រពៃណីជាដើម ។ល ។ បែរមកផ្នែកអក្សរសិល្ប៍វិញ ជាតិខ្មែរក៏បាន ទទួលយកនូវខ្លឹមសារៈប្រយោជន៍សំខាន់ៗពីមូលដ្ឋាននៃការឆ្លាក់គំនិត មនសិការ និងសតិស្មារតីជាតិនិយម យ៉ាងវិសេសវិសាលពណ្ណរាយដូចគ្នាដែរ ។

## អ្វីទៅជាការប៉ិនប្រសប់?

១. ការប៉ិនប្រសប់សំដៅលើគំនិតដើមបំផុតរបស់បុគ្គលណាមួយ ដែលផុសចេញពីការយល់ឃើញ ថ្មី ហើយប្លែក ហើយមិនចម្លងគំនិតឬបែបបថរបស់នរណាទាំងអស់ ។ ការយល់ឃើញគំនិតថ្មីៗ ប្លែកៗ ជាកត្តានាំអោយមានការរីកចំរើនក្នុងសង្គមជាតិ ។ ប៉ុន្តែគំនិតនិងគំហើញថ្មីៗទាំងឡាយមិនប្រាកដថា ជាគំនិតដែលនាំមកនូវសារប្រយោជន៍ល្អជូនសង្គមវិញរហូតនោះទេ ។ ដូច្នេះហើយ នៅមុនពេលត្រងទទួលយកគំនិតថ្មីនោះ យើងម្នាក់ៗគួរពិចារណាឲ្យបានច្បាស់លាស់ជាមុនសិនថា តើគំនិតថ្មីៗទាំងឡាយនោះផ្តល់គុណប្រយោជន៍ដល់មនុស្សក្នុងសង្គមយ៉ាងណាខ្លះ ។ ទន្ទឹមគ្នានេះ គំនិតចាស់បុរាណខ្លះវិញក៏មិនប្រាកដថាល្អទាំងអស់នោះដែរ មានន័យថា ទោះបីគំនិតចាស់បុរាណក៏ដោយ ទោះគំនិតថ្មីក៏ដោយ បើសិនគំនិតទាំងឡាយនោះអាចក្លាយជាឧបសគ្គនៃការវិវឌ្ឍន៍រុងរឿងប្រសើររបស់ប្រជាពលរដ្ឋក្នុងសង្គមគ្រាបច្ចុប្បន្ន យើងទាំងឡាយមិនគួរនឹងត្រងទទួលយកឥទ្ធិពលទាំងនោះមកផ្សព្វផ្សាយឬអនុវត្តន៍ឡើយ ។
២. គំនិតដែលប្រសប់ប្រសើរតែងផ្តល់នូវគុណប្រយោជន៍ ចំពោះសង្គមជាតិជានិច្ច ។ រីឯការអនុវត្តន៍នូវគំនិតថ្មីៗទៅលើផ្លូវជីវិតរស់នៅ ពិតជាសំខាន់ណាស់ ព្រោះថា គំនិតខ្លះអាចនាំមកនូវទុក្ខទោសអំពល់ត្រឡប់ដល់បុគ្គលឬដល់សង្គមវិញ ប្រៀបដូចជាកាំបិតដែលគេសំលៀងយ៉ាងមុត អាចយកមកប្រើជា

ប្រយោជន៍សម្រាប់ការរស់នៅ តែគេក៏អាចយកទៅប្រើជាអាវុធ ដើម្បីនឹងបំផ្លិចបំផ្លាញជីវិតមនុស្សយ៉ាងសាហាវវិញបានដែរ ។ ដូច្នេះគោលគំនិតប៉ិនប្រសប់ដ៏ពិតនោះ ចាំបាច់ត្រូវនាំនូវគុណប្រយោជន៍ល្អប្រពៃដល់មនុស្សជាតិក្នុងសង្គម តាមរយៈការអនុវត្តន៍គំនិតទៅក្នុងជីវិតដោយប្រពៃផង ។

៣. គំនិតថ្មីៗដែលនាំគុណសារៈប្រយោជន៍ត្រូវតែមានប្រសិទ្ធភាព ។ ប្រសិទ្ធភាពសំដៅទៅលើវិធីដោះស្រាយបញ្ហាអោយដល់គោលដៅដោយជោគជ័យ ។ បើគ្មានប្រសិទ្ធភាពទេ ទោះបីជាគំនិតនោះថ្មីយ៉ាងណាក៏អាចសាបរលាបទៅវិញដោយងាយដែរ ត្បិតថាបើគំនិតថ្មីនោះមិនអាចយកប្រើជាការបាន តើជនណានឹងជ្រើសរើសយកទៅអនុវត្តន៍ក្នុងជីវិតអោយចម្រុងចម្រើនការរស់នៅរបស់គេ ? ហើយបើគ្មានមនុស្សណាទទួលយកគំនិតថ្មីទាំងនោះទៅអនុវត្តទេ តើធ្វើម្តេចគេនឹងអាចបង្កបង្កើនប្រយោជន៍ដល់មនុស្សជាតិក្នុងសង្គមអោយជោគជ័យយ៉ាងណាបានទៅ ? ដូច្នេះ ការដែលយើងអាចត្រិះរិះរកឃើញនូវគំនិតដ៏ប្រសប់ចំណានណាមួយហើយ យើងគប្បីស្វែងរកវិធីប្រើប្រាស់ពិសោធន៍គំនិតនោះទៅក្នុងជីវិតវិញ ថាតើមានប្រសិទ្ធភាពទៅលើសង្គមដែរឬយ៉ាងណា ។ កាលបើគំនិតទាំងនោះអាចយកប្រើជាប្រយោជន៍ដោយប្រពៃបាន នោះទើបអាចហៅថាជាការប៉ិនប្រសប់របស់អ្នកបង្កើតគំនិតនិងអ្នករចនាគំនិត អោយក្លាយទៅជាផលប្រយោជន៍ដ៏មានតម្លៃ ក្នុងជីវិតរស់នៅរបស់ពលរដ្ឋ ។

**៤.** ការប៉ិនប្រសប់តែងនាំមកនូវគុណសម្បត្តិល្អសម្រាប់ជីវិតរស់នៅ ពោលគឺសំដៅលើការដែលយើងអាចធ្វើអោយការរស់នៅរបស់មនុស្សកាន់តែមានភាពងាយស្រួល ហើយសុខសប្បាយជាងមុន ចម្រុងចម្រើនជឿនលឿនហើយមានរបៀបមានសណ្តាប់ធ្នាប់របៀបរៀបរយនិង មានសុវត្ថិភាព ឧទាហរណ៍ សូមក្រឡេកមើលការវិវឌ្ឍន៍ក្នុងវិស័យធ្វើដំណើរគឺចាប់ តាំងពីការធ្វើដំណើរដោយជើងនៅនាសម័យបុរាណរហូតមកដល់កាលវេលាដែលមនុស្សធ្វើដំណើរតាម យន្តហោះឆ្លងទ្វីបនៅក្នុងសម័យកាលបច្ចុប្បន្ន នោះយើងនឹងឃើញថាការវិវឌ្ឍន៍ក្នុងមធ្យោបាយធ្វើដំណើរ កាន់តែមានភាពងាយស្រួល កាន់តែរហ័ស កាន់តែបានឆ្ងាយ ឆ្លងដែនដីដែនសមុទ្ទទាំងឡាយក្នុងសកលលោក ទាំងមូល ។ ដូច្នេះ ការរស់នៅមានភាពងាយស្រួលប្រសើរក្នុងជីវិតជាងមុនជាលទ្ធផលនៃគំនិតប៉ិនប្រសប់របស់ជនដែលមានប្រាជ្ញា ហើយការប៉ិនប្រសប់ខាងរចនាគំនិតអោយចេញជារូបរាងបានយ៉ាងប្រសើរនេះ គឺជាគន្លឹះនៃការវិវឌ្ឍន៍យ៉ាងធុំធ្លើងរបស់សង្គមជាតិទាំងមូល ។

# អ្វីទៅជាការប៉ិនប្រសប់របស់អ្នកនិពន្ធ ?

ស្មារតីដ៏សំខាន់របស់កវីនិពន្ធគ្រប់រូបគឺការបណ្តុះថ្មីដែរឲ្យកាន់តែប្រសប់ប្រសើរ ។ ដើម្បីនឹងដុសខាត់ថ្វីដៃនិពន្ធរបស់ខ្លួនអោយកាន់តែកើនឧត្តមភាព តើអ្នកនិពន្ធនិមួយៗគួរបណ្តុះទេពកោសល្យយ៉ាងណាខ្លះ ?

## ១. គំនិតដើម:

ដើម្បីជាសក្ខីភាពនៃស្នាដៃប៉ិនប្រសប់ អ្នកនិពន្ធទាំងឡាយចាំបាច់ត្រូវតែរក្សាគំនិតដើមរបស់ខ្លួន គឺជាគំនិតដែលផ្តល់នូវសារៈប្រយោជន៍ដ៏ប្រសិទ្ធ និងផ្តល់នូវគុណសម្បត្តិល្អចំពោះជីវិតមនុស្ស ។ **គំនិតដើម** សំដៅទៅលើគំហើញផ្ទាល់របស់ស្មេរទៅលើចំណុចសំខាន់អ្វីមួយក្នុងសង្គម រួចហើយអ្នកនិពន្ធនោះសរសេរ

Email: nphalla@hotmail.com

ផ្តល់នូវគំនិតដោះស្រាយ ដើម្បីស្វែងរកវិធីបណ្តុះការចម្រើនវិវឌ្ឍន៍របស់មនុស្សជាតិ ដោយមិនចម្លងគំនិតពីបុគ្គលណាម្នាក់ដដែលជាងដែលទៀតឡើយ ។ ទម្លាប់មិនល្អមួយដែលជាឧបសគ្គនៃការរីកចំរើនរបស់ខ្មែរ គឺការកត់ចម្លងគំនិតពីជនដទៃដោយខ្វះការពិចារណា និងការសរសេរដោយខ្វះគោលឧបាយសម្រាប់ដោះស្រាយជីវិត ។ នៅបច្ចុប្បន្ននេះ គំនិតចាស់បុរាណខ្លះបានសាបរលាបអស់ប្រសិទ្ធភាព សម្រាប់យកមកប្រើដើម្បីដោះស្រាយជីវិតរស់នៅក្នុងសង្គម ថ្វីបើគំនិតខ្លះទៀតនៅមានប្រសិទ្ធភាពនៅឡើយ ។ ដូច្នេះ នៅសម័យកាលបច្ចុប្បន្ននេះ បើសិនយើងទាំងឡាយមិនព្យាយាមបណ្តុះគោលគំនិតល្អៗ ថ្មីៗ ដ៏ប្រសិទ្ធបន្ថែមទៀតទេ នោះសង្គមខ្មែរនឹងថមថយការរីកចម្រើនរុងរឿងជាមិនខាន ជាពិសេស ខាងសីលធម៌ សង្គមធិគុណធម៌ និងវប្បធម៌នេះតែម្តង ។ ការដែលអ្នកនិពន្ធបានរកឃើញនូវគំនិតថ្មីហើយប្លែកពីធម្មតា ហើយក៏ជាគំនិតដែលអាចផ្តល់ប្រសិទ្ធភាពប្រសើរចំពោះអ្នកអាននិងប្រជាជនទូទៅក្នុងសង្គម នោះជាកត្តាបង្ហាញនូវគំនិតដ៏ប៉ិនប្រសប់របស់អ្នកនិពន្ធរូបនោះ ហើយក៏ជាមោទនភាពរបស់ខ្មែរយ៉ាងខ្ពង់ខ្ពស់ឧត្តុង្គឧត្តម គួរជាទីកត់សំគាល់របស់សង្គមជាតិទាំងមូល ។

## ២. គុណប្រយោជន៍:

នេះជាការសំដៅទៅលើតម្លៃអត្ថបទដែលនាំមកនូវសារប្រយោជន៍ដល់អ្នកអាន មានដូចជា:

***២ក- ការផ្តល់នូវដំណោះស្រាយ:*** អ្នកនិពន្ធគប្បីសរសេរផ្តល់នូវដំណោះស្រាយប្លែកៗក្នុងសាច់រឿងដោយកត្តាសមហេតុសមផលហើយប្រពៃ ដើម្បីឲ្យអ្នកអានបានយកទៅត្រិះរិះពិចារណាក្នុងការត្រងមតិក្នុងសំណេរដើម្បីយកទៅអនុវត្តន៍ក្នុងជីវិតអោយបានរុងរឿង មានន័យថា ការដែលអ្នកនិពន្ធសរសេរត្រឹមតែជាការត្អូញត្អែរិះគន់អំពីចំណុចបញ្ហាអ្វីមួយ ដោយគ្មានផ្តល់នូវគំនិតប្រសើរៗប្លែកៗ សម្រាប់ដោះស្រាយវិបត្តិទាំងឡាយអោយបានធូរស្រាល នៅទីបញ្ចប់ គឺគ្រាន់តែជាការសរសេរបញ្ឆោះដល់សង្គម យ៉ាងអាសារបង់តែប៉ុណ្ណោះ ។ ការសរសេរបន្ថែមនូវវិធីដោះស្រាយនានាដើម្បីរកច្រកចេញពីចំណុចបញ្ហាដែលអ្នកនិពន្ធកំពុងលើកយកមកពិភាក្សា នោះទើបជាខ្លឹមសារពិតប្រាកដរបស់អក្សរសិល្បិ៍ដែលអាចនាំសារប្រយោជន៍ប្រពៃដល់អ្នកអានទាំងឡាយនិងដល់សង្គមជាតិទាំងមូល ។

***២ខ- ការផ្តល់ជាយោបល់ដល់អ្នកអាន:*** នៅក្នុងសំណេរខ្លះៗ អ្នកនិពន្ធក៏អាចផ្តល់ជាគំនិតយោបល់ ថ្មីៗប្លែកៗ គ្រាន់អោយអ្នកអានយកទៅវិភាគ ថាតើការយល់ឃើញរបស់អ្នកនិពន្ធត្រឹមត្រូវប៉ុនណា ល្អយ៉ាងណា ប្រសើរយ៉ាងណា ប្លែកយ៉ាងណា មានតម្លៃប៉ុនណា ជាដើម ដើម្បីជួយមនុស្សយកទៅអនុវត្តន៍ការងារក្នុងជីវិតអោយបានចម្រុងចម្រើន ត្បិតមានពេលខ្លះ អ្នកអានមានបំណងស្វែងរកត្រឹមតែជាយោបល់ប្លែកៗក្នុងបំណងបណ្តុះបណ្តាលសតិស្មារតី និង ចំណេះវិជ្ជាដើម្បីវិវឌ្ឍន៍ការចេះដឹងរបស់ខ្លួនអោយកាន់តែប្រសើរថែមទៀតតែប៉ុណ្ណោះ ថ្វីបើគេមិនទាន់អាចយកគំនិតទៅអនុវត្តន៍ក្នុងជីវិតបាននៅឡើយក្តី ឧទាហរណ៍ ដូចជាអ្នកអានដែលជាសិស្សនិស្សិតកំពុងសិក្សាជាដើម ។ ដូច្នេះ ការផ្តល់ជាមតិយោបល់ប្លែកៗជាកត្តាអាចនាំគុណប្រយោជន៍ល្អប្រសើរជូនសង្គម នៅពេលអនាគត ។ នៅគ្រាណាមួយដែលអ្នកអានមានឱកាសទទួលយកគំនិតនោះទៅអនុវត្តន៍ហើយបានទទួលនូវភាពរីកចម្រើនក្នុងជីវិត ពេលនោះគំនិតរបស់អ្នកនិពន្ធក៏ប្រែក្លាយទៅជាគំនិតណែនាំដ៏ប្រសិទ្ធសម្រាប់សង្គមជាតិដែរ ។

***២គ- ការផ្តល់នូវដំបូន្មានណែនាំ:*** គឺជាការសរសេរអត្ថបទអប់រំប្រៀនប្រដៅដល់មនុស្សជំនាន់ក្រោយដោយបែបបទប្រពៃ ដូចជា ការសរសេរទូន្មានអប់រំជាសុភាសិត ជាកំណាព្យ ជាទំនុកច្រៀង ឬក៏ជាអត្ថបទអក្សរសិល្ប៍ដទៃៗទៀតជាដើម ។ល ។ សព្វថ្ងៃនេះ អត្ថបទអក្សរសិល្ប៍ដែលដូនតាខ្មែរបានចងក្រងទុកជាច្រើនកន្លងមកនោះ ក៏នៅរក្សាប្រសិទ្ធិភាពរបស់អត្ថបទយ៉ាងវិសេសវិសាលនាបច្ចុប្បន្ននេះដដែល ត្បិតពលរដ្ឋនៅក្នុងសង្គមនៅតែទទួលយកមកអនុវត្តន៍ក្នុងជីវិតរបស់គេនៅឡើយ ថែមទាំងអាចទាញយកបាននូវគុណប្រយោជន៍យ៉ាងប្រសើរ ពីការអនុវត្តន៍គោលគំនិតអប់រំនោះ មិនចាញ់គ្នាពីពេលបុរាណឡើយ ឧទាហរណ៍ ដូចជាសុភាសិតដែលចែងថា "ចង់ចេះឲ្យសម្លាប់អាចារ្យ ចង់បានផ្លែផ្កា យកភ្លើងដុតគល់ "... "ចង់ចេះអោយខំរៀន ចង់មានអោយខំរក " ..."ចង់រាក់អោយដីក ចង់រីកអោយ ហាលថ្ងៃ" នោះជាដើម សុទ្ធសឹងតែជាពាក្យប្រស្ពាដាស់តឿនក្រើនរំលឹកនូវសតិស្មារតីទទួលខុសត្រូវ លើកតម្កើងនិងជំរុញសេចក្តីព្យាយាមដែលអាចញាំងជីវិតរបស់មនុស្សអោយកាន់តែបានទទួលនូវភាពចំរុងចម្រើនប្រសើរជាងមុនបន្ថែមទៀត ។

***២ឃ- ការផ្តល់នូវចំណេះវិជ្ជានិងវិជ្ជាជីវៈល្អៗ:*** គឺជាគំនិតណែនាំល្អៗក្នុងការបណ្តុះបណ្តាលជនាញក្នុងជីវិតដើម្បីផ្លាស់ប្តូរជីវភាពរស់នៅអោយកាន់តែប្រសើរ ដូចជាវិធីធ្វើស្រែ ធ្វើចំការអោយបានភោគផលច្រើនបរិបូណ៌ វិធីទាញយកថាមពលពីខ្យល់ពីព្រះអាទិត្យដើម្បីប្រើប្រាស់សម្រួលជីវិតប្រចាំថ្ងៃ វិធីជួសជុលកង់ ជួសជុលម៉ូតូ វិធីដាំស្លជាដើម វិធីថែរក្សាសុខភាពនិងអនាម័យ វិធីថែទាំបរិដ្ឋាន វិធីអប់រំសង្គម វិធីរំលត់ទោសៈ វិធីរក្សាសុភមង្គលគ្រួសារ វិធីដេរប៉ាក់ វិធីដុសខាត់ជំនាញនានាដទៃទៀត ។ល ។

# ៣. ប្រសិទ្ធភាព:

ដើម្បីអោយមានប្រសិទ្ធភាពពេញលក្ខណៈ សំណេរទាំងឡាយត្រូវមានរួមបញ្ចូល នូវចំណុចលក្ខណៈល្អៗជាច្រើនយ៉ាង ដូចជា:

***៣ក- ខ្លឹមរសរបស់សំណេរ:*** គឺការសរសេរនិពន្ធមានវគ្គ មានឃ្លា ត្រឹមត្រូវតាមវេយ្យាករណ៍ និងក្បួនសរសេរនិពន្ធ ដូចជា មានផ្តើមសេចក្តី មានតួសេចក្តី មានទីបញ្ចប់ ងាយយល់ ងាយអាន ហើយមិនវង្វេងគំនិតដែលអ្នកនិពន្ធបានបង្កប់នៅក្នុងសាច់រឿង ។ អត្ថបទដែលមានអត្ថរសបំផុតគឺជាសំណេរដែលខ្លីតែមានន័យវែងឆ្ងាយទូលំទូលាយច្រើនបែបច្រើនយ៉ាង នោះប្រសើរជាជាងការសរសេររៀបរាប់វែងអន្លាយឆ្ងាយចាកប្រធាន ដែលធ្វើអោយពំនូតអត្ថន័យរបស់សំណេរនិពន្ធ បែរក្លាយទៅជាតូចស្តួចស្តើងទៅវិញ ។

***៣ខ- ការស្រាយចម្ងល់ ឬបញ្ហា:*** គឺជាការវែកញែកនូវសព្វជ្រុងជ្រោយ ក្នុងការដោះស្រាយចំណុចបញ្ហានិមួយៗនៃសំណេរអត្ថបទ ដោយច្បាស់លាស់ហើយសមហេតុសមផល ពោលគឺជាការសរសេរនិពន្ធដឹកនាំអ្នកអានអោយបណ្តុះនិងរក្សាសតិស្មារតី អោយកាន់តែជួបនឹងភាពភ្លឺស្វាងរឹងមាំប្រសើរឡើង មិនថមថយ ។ នេះជាការសរសេរប្រកបដោយសតិប្រាជ្ញ ចេះចងគំនួចរឿងហើយក៏ចេះស្រាយយ៉ាងពិរោះពិស្តារមានអត្ថន័យគួរជាទីសណ្តាប់និងមានតម្លៃសមហេតុផលគួរត្រងទទួលយក ។ អត្ថបទរបៀបនេះច្រើនមានតម្លៃស្ថិតស្ថេរចេរកាលយូរលង់នៅក្នុងប្រវត្តិអក្សរសិល្ប៍ ។

*៣គ- **ការបង្កើននូវកិរិតវិជ្ជានិងការចេះដឹងរបស់អ្នកអាន:*** ជោគជ័យប្រសើររបស់អ្នកនិពន្ធ គឺជាសមត្ថភាពដ៏ពូកែរបស់អ្នកនិពន្ធក្នុងការទាញអ្នកអានអោយផ្លាស់ប្តូរ ពីភាពល្ងិតមករកភាពភ្លឺថ្លាក្នុងជីវិត ផ្លាស់ពីភាពល្ងង់មកភាពឆ្លៀវឆ្លាតជាងមុន មានការចេះដឹងជាងមុន តាមរយ:សំណេរអត្ថបទអក្សរសិល្ប៍របស់អ្នកនិពន្ធនោះឯង ។ ដូច្នេះ ស្មេរនិមួយៗគប្បីរក្សាប្រសិទ្ធភាពនៃការសរសេរអោយបានល្អប្រសើរច្រើនចំណុច នៅក្នុងសំណេររបស់ខ្លួន ដោយការបញ្ចូលនូវគំនិតប្រពៃប្លែកៗ ដែលនាំនូវសារប្រយោជន៍ប្រសប់ប្រសើរ ដល់អ្នកអានទាំងឡាយ ។ កាលបើអ្នកអានបានទទួលនូវភាពភ្លឺស្វាងនិងចំណេះចេះដឹងដែលផ្តល់នូវគុណប្រយោជន៍សំខាន់ហើយល្អៗដល់ជីវិតរបស់គេ អត្ថបទអក្សរសិល្ប៍នោះតែងបានទទួលនូវការគាំទ្រនិងលើកតម្កើងពីសំណាក់ពលរដ្ឋក្នុងសង្គមយ៉ាងប្រសើរឧត្តម ។

## *៤. គុណសម្បត្តិរបស់សំណេរ:*

*នោះគឺជាការសរសេរនិពន្ធដែលអាចធ្វើអោយជីវិតអ្នកអានបានជួប និងបានទទួលនូវប្រាជ្ញាភ្លឺស្វាង មានការចេះដឹងជាងមុន និងមានភាពស្រស់ថ្លាក្នុងចិត្ត ក្នុងអារម្មណ៍ ក្នុងគំនិត ក្នុងសតិ ក្នុងជីវិត ជាងមុន បន្ទាប់ពីបានអានគំនិតសិក្សានៅក្នុងអត្ថបទរបស់ស្មេររួចហើយ ។ កាលបើពលរដ្ឋបានទទួលការរីកចំរើនថ្កុំថ្កើងតាមរយ:ឥទ្ធិពលនៃទឹកខ្មៅអក្សរសិល្ប៍ហើយ សង្គមជាតិក៏មានដំណើររីកចំរើនដុះដាលទៅតាមល្បឿននៃការចេះដឹងរបស់ពលរដ្ឋទៅតាមនោះដែរ ។ រីឯអ្នកអានវិញនោះ ក្រោយពីគេបានអានសំណេរដ៏មានតម្លៃទាំងអស់នោះហើយ គេក៏កាន់តែមានចំណូលចិត្ត កាន់តែមានដួងចិត្តរីករាយ កាន់តែទទួលនូវសេចក្តីសុខរមនានៅក្នុងអារម្មណ៍ ។ លុះនៅគ្រាបន្តបន្ទាប់មក គេក៏នឹងផ្សព្វផ្សាយនូវសមត្ថភាពផ្នែកសតិប្រាជ្ញ ការចេះដឹង និងភាពរីកចំរើនរបស់ខ្លួន ទៅពលរដ្ឋផ្សេងទៀតក្នុងសង្គម ជាបន្តៗ គ្មានទីបញ្ចប់ឡើយ ។ នោះហើយជាគុណសម្បត្តិយ៉ាងប្រសិទ្ធរបស់សំណេរអក្សរសិល្ប៍និពន្ធ ។*

# តើអ្នកនិពន្ធត្រូវបណ្តុះការប៉ិនប្រសប់ដោយរបៀបណា ?

នេះជាការងាយស្រួលបំផុត ចំពោះអ្នកនិពន្ធដែលចង់បណ្តុះបណ្តាលភាពប៉ិនប្រសប់របស់ខ្លួន អោយកាន់តែប្រសើរឡើងៗ ។ ស្មេរទាំងឡាយត្រូវសិក្សាហ្វឹកហ្វឺនតែប៉ុន្មានចំណុចសំខាន់ៗប៉ុណ្ណោះ ដើម្បីបង្កើនទឹកដមប៉ាកកាអោយកាន់តែមានប្រសិទ្ធភាពនិងកាន់តែបង្កើនគុណសម្បត្តិជូនសង្គមជាតិរបស់យើង ដូចជា :

## *១. ការគិតក្នុងផ្លូវល្អ:*

- *អ្នកនិពន្ធទាំងឡាយគប្បីសម្លឹងមើលចំណុចសំខាន់ណា ដែលជាកត្តាលក្ខណ:គុណសម្បត្តិល្អប្រសើរដោយការលើកទឹកចិត្តមនុស្ស អោយប្រព្រឹត្តអំពើប្រពៃ ហើយព្យាយាមតស៊ូកសាងខ្លួនក្នុងអំពើល្អហើយថ្លៃថ្នូរ ជាជាងសរសេរច្បាមច្បិចនូវគុណវិបត្តិរបស់បុគ្គលណាមួយ ពោលគឺមិនស្វែងរកចាប់កំហុសអ្នកដទៃ ដើម្បីចំអកឡកឡឺយបញ្ជោះបន្សោកឡើយ ព្រោះការសរសេរបែបនោះអាចធ្វើអោយអ្នកអានទាំងឡាយមានការធុញថប់ទើសទាល់ក្នុងចិត្តគ្រប់ៗគ្នា ។*

- រៀនកែកំហុសនៅមុនពេលប្រព្រឹត្តខុស ដោយការសម្លឹងមើលកំហុសអ្នកដទៃ ហើយរៀនកែប្រែជីវិត ដោយមិនចាំបាច់ប្រព្រឹត្តកំហុសដោយខ្លួនឯង ។
- រក្សាស្មារតីនិងគំនិតសុទដ្ឋិ ដោយសម្លឹងមើលបញ្ហាជីវិតអោយបានសព្វជ្រុងជ្រោយ ដើម្បីរកវិធីដោះស្រាយបញ្ហាក្នុងជីវិតនានាអោយបានភ្លឺស្វាង ហើយធូរស្រាលជាងមុន ប្រសើរជាជាងនៅអង្គុយត្អូញត្អែរអ៊ូអរស់សង្ឃឹមរួចស្តីបន្ទោសតែព្រហ្មលិខិតតែម្យ៉ាង ពោលគឺរក្សាខ្លួនដោយមិនបណ្តោយអោយខ្លួនឃ្លាតចាកក្តីសង្ឃឹមទាល់ច្រកអស់ផ្លូវដើរ ថែមទាំងអាចរៀនចេះបត់បែន តាមកាលៈទេសៈដែលសមគួរ ។
- រក្សាគំនិតនិងស្មារតីដោយឈរនៅលើឆន្ទៈ "ខ្លួនទីពឹងខ្លួន" ជាមូលដ្ឋាន ក្នុងការបណ្តុះសមត្ថភាពរបស់ខ្លួនអោយកាន់តែប្រសប់ប្រសើរនិងថ្លៃថ្នូរ ។
- ហ៊ានត្រងទទួលការរិះគន់ពីសំណាក់អ្នកអានទាំងវិជ្ជមាននិងអវិជ្ជមាន ដើម្បីជាគោលស្វែងរកគន្លឹះកែលំអអោយកាន់តែប្រសើរ ដោយទន្ទឹស្ងប់ប្រសើរ មិនច្រឡោតខឹង មិនបញ្ឆោះបន្ទោកតបវិញមិនតវ៉ាប្រឆាំងជាដើម ។ ផ្ទុយទៅវិញ ស្មេរត្រូវរក្សាអារម្មណ៍ ស្ងប់ស្ងៀមហើយផ្ទៀងផ្ទាត់ស្តាប់នូវគំនិតយោបល់ទាំងនោះ ក្រែងលោយោបល់ទាំងឡាយនោះជាគន្លឹះទ្រឹស្តីអប់រំដ៏មានប្រយោជន៍ប្រសើរដល់យើងជាអ្នកនិពន្ធ និងដល់អ្នកអានដទៃ ថែមទៀត ។

## ២. ការពូកែសង្កេតៈ

អ្នកនិពន្ធនិមួយៗត្រូវពូកែពិនិត្យសម្លឹង ស្រាវជ្រាវ ហើយត្រងទទួលយកមកសិក្សានូវគំនិតអ្វីដែលប្លែកដែលថ្មី ហើយមានលក្ខណៈប្រសើរសម្រាប់សង្គមជាតិ ដោយយកស្មារតីជាតិនិយមជាជំហរ ក្នុងការឈានឆ្ពោះទៅរកការរីកចម្រើននិងចំណេះដឹងកាន់តែប្រសើរ ។ ការសង្កេតពិនិត្យនាំអោយយើងមានការពិចារណា ។ ឯការពិចារណាច្រើនធ្វើអោយយើងដុះដាលគំនិតកាន់តែច្រើន ។ នៅពេលនោះឯងហើយដែលអ្នកនិពន្ធម្នាក់ៗត្រូវប្រើសតិប្រាជ្ញាវែកញែកគំនិតថ្មីទាំងនោះនៅក្នុងសំណេររបស់ខ្លួន អោយល្អក្បោះក្បាយ ហើយថែមទាំងបញ្ចូលនូវមតិរបស់អ្នកនិពន្ធដែលប្លែកហើយមានប្រយោជន៍ដល់អ្នកអានដើម្បីអោយគេមានឱកាសយកគំនិត យកមតិយោបល់ទាំងនោះ ទៅសិក្សាដូចគ្នាដែរ ។ ការដែលអ្នកអាននិងអ្នកនិពន្ធអាចបំបែកគំនិតល្អៗអោយបានកាន់តែច្រើន ការវិវត្តន៍ផ្នែកគំនិតប្រាជ្ញានិងសតិស្មារតីក៏មានការរីកចំរើនរុងរឿង ទៅតាមនោះដែរ ។

## ៣. ការជៀសវាងសំណេរឥតខ្លឹមប្រយោជន៍ៈ

អ្នកនិពន្ធគួរចៀសវាងការសរសេរនិពន្ធអត្ថបទទាំងឡាយណាដែលធ្វើអោយអ្នកអានថមថយកម្លាំងសតិថមថយស្មារតីជាតិនិយម ស្រកគុណធម៌ ស្រកសុជីវធម៌ ស្រកសីលធម៌និងវប្បធម៌ ខាតក្រដាសនិងទឹកខ្មៅជាដើម ខាតទាំងពេលវេលាអាន ឧទាហរណ៍ ដូចជាការសរសេរត្អូញត្អែរ ការសរសេររិះគន់ការសរសេរអារាត់អារាយ ការយំទួញសោកស្តាយស្រណោះ ការសរសេរប្រោកប្រាជ្ញឥតន័យ ការសរសេរដើម្បីបង្កកំហឹងបណ្តុះគំនុំ ដោយមិនមានការសរសេរបន្ទរសាច់រឿងដោយការដោះស្រាយវិបត្តិ

នៅក្នុងសំណេរ សុទ្ធសឹងជាអត្ថបទដែលពុំមានផ្តល់រសជាតិប្រសើរដល់សង្គមអ្នកអានអ្វីបន្តិចសោះឡើយ ។

## ៤. ស្មារតីជាតិនិយម ឬមោទនៈភាពជាខ្មែរ:

នេះគឺជាស្មារតីស្រឡាញ់ប្រទេសជាតិខ្លួន ស្រឡាញ់តម្លៃអត្តសញ្ញាណរបស់ខ្លួនជាខ្មែរ ស្រឡាញ់ផ្ទះសម្បែង ភូមិស្រុក ដីធ្លី និង សង្គមខ្លួន ។ កាលបើមានក្តីស្រឡាញ់ហើយ មនុស្សនឹងថែរក្សាអ្វីដែលជាទីស្រឡាញ់នោះមិនអោយបាត់បង់ទៅវិញឡើយ ។ មិនតែប៉ុណ្ណោះ គេថែមទាំងបណ្តុះបណ្តាល កែសម្រួល និងលើកតម្កើងឲ្យកាន់តែល្អប្រសើរ ដោយមិនអនុញ្ញាតិអោយឥទ្ធិពលបរទេសចូលមកជ្រៀតជ្រែក ដណ្តប់លើសង្គមជាតិរបស់ខ្លួនបាន ដូចជា ការមិនប្រើប្រាស់ភាសាបរទេសក្នុងសង្គមជំនួសភាសាខ្មែរ ការមិនទទួលគំនិតភ្លើតភ្លើនផ្តេសផ្តាសពីបរទេសដែលធ្វើឲ្យខូចសីលធម៌និងសង្គមធម៌របស់ជាតិខ្មែរជាដើម ។ នេះមិនមែនមានន័យថាយើងនាំគ្នាទាញប្រទេសខ្មែរមិនអោយអភិវឌ្ឍន៍រុងរឿងនោះទេ តែមានន័យថា អ្វីដែលជាឥទ្ធិពលមិនថ្លៃថ្នូរ មិនប្រពៃ សម្រាប់សង្គមខ្មែរ យើងមិនគួរទទួលយកឥទ្ធិពលទាំងនោះមកផ្សព្វផ្សាយអោយពលរដ្ឋខ្មែរនាំគ្នាវង្វេងភ្លើតភ្លើនបាត់សតិប្រាជ្ញា និងស្មារតីជាតិនិយមនោះឡើយ ។ យើងគប្បីចងចាំអោយជាក់ច្បាស់នៅក្នុងដួងចិត្តថា បើសិនខ្មែរមិនស្រលាញ់ខ្មែរខ្លួនឯង តើអោយសាសន៍ណាមកស្រឡាញ់ខ្មែរជំនួសយើង ? បើខ្មែរមិនថែរក្សាអ្វីទាំងឡាយណាដែលជាធនធានរបស់ខ្មែរ តើសាសន៍ណានិងមកថែរក្សាជាតិខ្មែរអោយដូចជាយើងថែរក្សាដោយខ្លួនឯងនោះ ? បុព្វបុរសខ្មែរបានជ្រើសរើសយកចំណុចសតិល្អៗជាច្រើនពីពុទ្ធសាសនាមកកែឆ្នៃសង្គមអោយកាន់តែប្រសើរ មានសេចក្តីក្សេមក្សាន្ត និងមានការវិវត្តន៍រុងរឿង ដោយសន្តិ ។ ក្រៅពីជំនឿនិងសាសនា ខ្មែរក៏បានទទួលយកឥទ្ធិពលផ្សេងទៀត មានដូចជា បច្ចេកវិជ្ជា វិទ្យាសាស្ត្រ វប្បធម៌ និងអរិយធម៌ពីបរទេសខ្លះថែមទៀត ។ ប៉ុន្តែទោះជាយ៉ាងនេះក្តី ខ្មែរដែលជាអ្នកប៉ិនប្រសប់ច្រើនប្រើទេពកោសល្យក្នុងការជ្រើសរើសឥទ្ធិពលទាំងនោះ ដោយការពិចារណាយកចិត្តទុកដាក់ជាទីបំផុត មិនមែនចេះតែទទួលយកទាំងស្រុងៗទាំងងងឹតងងល់នោះឡើយ ពោលគឺគេជ្រើសរើសយកតែចំណុចដែលល្អៗមកផ្សព្វផ្សាយនិងអនុវត្តន៍សម្រាប់ការរីកចម្រើនប្រសើរថ្លៃថ្នូរ សម្រាប់សង្គមខ្មែរ តែម្យ៉ាងប៉ុណ្ណោះ ។

## ៥. ការយកខ្លួនឯងជាទីពឹងនូវពេលប្រទះនឹងបញ្ហា:

ស្មេរទាំងឡាយគប្បីផ្តល់ជាយោបល់ថ្មីៗ ប្លែកៗ ខ្លះៗ ដើម្បីជួយអោយមិត្រអ្នកអានត្រងយកទៅគិតពិចារណាផងដែរថា តើដំណោះស្រាយនោះអាចមានសារៈប្រយោជន៍យ៉ាងណាខ្លះចំពោះជីវិតមនុស្សក្នុងសង្គម ។ បើសិនគ្រប់គ្នាលើកតែពីបញ្ហា ឬក៏ផ្តោតតែអារម្មណ៍ទៅលើតែរឿងស្រណោះស្រណោក ចងកំហឹងទោសៈ និន្ទារិះគន់ មើលបំណាំគ្នាមិនឈប់ឈរ រួចហើយម្នាក់ៗមិនព្រមនាំគ្នាជួយរកមធ្យោបាយដោះស្រាយនូវបញ្ហាអ្វីបន្តិចសោះ តើសង្គមជាតិនឹងប្រែក្លាយទៅជាយ៉ាងណាវិញ ? បើព្រះមានតែមួយអង្គ រីឯបញ្ហាមានរាប់មិនអស់ តើព្រះគួរយាងប្រោសដោយរបៀបណា បើជននិមួយៗមិនប្រឹងប្រែងរកវិធីដោះស្រាយដោយខ្លួនឯងខ្លះសោះនោះ ឬក៏គំនិតតូចតាចសម្រាប់ដោះស្រាយជីវិតក៏គ្មានដែរ ? ពុទ្ធភាសិតចែងថា ខ្លួនទីពឹងខ្លួន ។ ឯគ្រីស្តភាសិតវិញចែងថា ព្រះជួយជនណាដែលដើបជួយខ្លួនឯង ។

នេះមានន័យថា នៅពេលយើងគេងរំពឹងព្រះ (ព្រះព្រហ្ម ព្រះពុទ្ធ ព្រះគ្រីស្តជាដើម) យើងគប្បីគិតរំពឹងលើសតិប្រាជ្ញនិងសមត្ថភាពរបស់ខ្លួនជាមុនសិន នៅពេលយើងពើបប្រទះនឹងបញ្ហាជីវិត ។ ដូច្នេះអ្នកនិពន្ធដែលប៉ិនប្រសប់គឺជាស្មេរដែលមានទេពកោសល្យអាចជួយរកមធ្យោបាយផ្សេងៗ ដើម្បីជួយបណ្តុះគំនិតសតិប្រាជ្ញរបស់អ្នកអាន អោយមានកម្លាំងចិត្តខ្លាំងមុតមាំ មានជំនឿលើការតស៊ូព្យាយាម មានជំនឿជឿជាក់លើសមត្ថភាពរបស់ខ្លួនក្នុងការពុះពារឧបសគ្គ មានសតិដឹងខុសត្រូវ មានការពិចារណាម៉ត់ចត់ច្បាស់លាស់ មិនវង្វេងគំនិតស្មារតីចាកផុតក្តីសុចរិត សាមគ្គីភាព និងសន្តិភាពឡើយ ។

## ៦. ការប្រើប្រាជ្ញាស្មារតីមកពិចារណាថ្លឹងថ្លែងហេតុផល:

នេះជាការពិចារណាថាតើយ៉ាងណាជាខ្លឹមសារនៃអក្សរសិល្ប៍ដែលនាំអ្នកអានអោយដើរឆ្ពោះទៅរកភាពចំរុងចំរើន ។ ការដែលសរសេរដោយខ្វះសតិពិចារណា ហាក់ដូចជាការព្រលែងគោរឲ្យស៊ីស្មៅដោយសេរី ជួនក៏ប៉ះដល់ដំណាំអ្នកស្រុកដទៃ ជួនប៉ះលើដំណាំខ្លួនឯង ដែលអាចបណ្តាលអោយកើតមានក្តីសៅហ្មងតាមក្រោយមកទៀតបាន ។ ដូច្នេះហើយ ស្មេរនិមួយៗត្រូវថ្លឹងថ្លែងគំនិតរបស់ខ្លួនអោយបានច្បាស់លាស់នៅមុនពេលសម្រក់ទឹកខ្មៅលើក្រដាសចែកគេឯងអាន ដោយមិនសរសេរអ្វីឲ្យរួចតែពីដៃរបស់ខ្លួនឡើយ ។ ការដែលអ្នកនិពន្ធមានគំនិតប្រយ័ត្នប្រយែងយកចិត្តទុកដាក់ក្នុងការគិត ក្នុងការសរសេរ នោះសំណេរអក្សរសិល្ប៍របស់គេ ក៏នឹងមានរសជាតិ មានសារប្រយោជន៍ប្រសើរ ដល់អ្នកអាននានា មិនលែងឡើយ ហើយក៏អាចទទួលការគាំទ្រពីសង្គមជាតិយូរអង្វែងតទៅមុខ ។

# តើសិល្បៈក្នុងការសរសេរដែលមានតម្លៃនោះ មានលក្ខណៈយ៉ាងដូចម្តេច?

តម្លៃនៃអក្សរសិល្ប៍និមួយៗ គឺឋិតនៅត្រង់ការប៉ិនប្រសប់របស់អ្នកនិពន្ធ ក្នុងការផ្សព្វផ្សាយគំនិតដែលផុសចេញមកពីសតិនិងស្មារតីដ៏ប្រពៃរបស់អ្នកនិពន្ធផ្ទាល់តែម្តង ពោលគឺជាការនិពន្ធដែលនាំមកនូវអត្ថន័យជ្រៀលជ្រៅក្នុងសំណេរ ចំពោះអ្នកអានគ្រប់ស្រទាប់ អោយបានទទួលនូវខ្លឹមសារៈប្រយោជន៍ក្នុងជីវិតកាន់តែច្រើនជាងមុនបន្ទាប់ពីគេបាន អានសំណេរនោះរួចហើយ ។ នោះគឺជាចំណេះដឹងប្លែកៗ ល្អៗ សម្រាប់ជួយសម្រាយទុកកង្វល់របស់អ្នកអានផង សម្រាប់បណ្តុះសតិប្រាជ្ញារបស់អ្នកអានផង ប៉ុន្តែមិនមែនជាការសរសេរត្អូញត្អែរបង្វៃរអារម្មណ៍អោយអ្នកអាន រំជើបរំជួលចិត្តកើតទោសៈមោហៈថែមទៀតនោះឡើយ ។ សារៈប្រយោជន៍ដែលផុសចេញពីភាពប៉ិនប្រសប់របស់អ្នកនិពន្ធនេះហើយ ដែលជាតម្លៃស្នាដៃដ៏ពិសិដ្ឋរបស់អ្នកនិពន្ធតែម្តង ។

ឯស្នាដៃដ៏វិចិត្ររបស់អ្នកនិពន្ធខ្មែរដែលមានសារៈប្រយោជន៍ដល់សង្គមជាតិ ជាមរតកដែលបញ្ញវន្តខ្មែរតែងព្យាយាមរក្សា សម្រាប់ខ្មែរជំនាន់ក្រោយ ។ អក្សរសិល្ប៍ដែលមានតម្លៃខ្ពង់ខ្ពស់ គឺជាសំណេរដែលផ្តល់នូវគុណប្រយោជន៍ល្អៗដល់អ្នកអាន ដោយការដាស់តឿននូវស្មារតីឲ្យភ្ញាក់រលឹក ការរៃកញ្ញេកណៃនាំអោយមនុស្សកាន់តែប្រព្រឹត្តនូវអំពើល្អ ឬដោយការប្រៀនប្រាប់នូវគំនិតល្អៗ និងវិធីផ្សេងៗដែលមានប្រសិទ្ធភាព សម្រាប់ដោះស្រាយជីវិត ។ល ។ ជនជាតិខ្មែរដែលជាអ្នកកាន់ខ្ជាប់នូវព្រះពុទ្ធសាសនា តែងអប់រំខ្លួនអោយរក្សា សតិប្រាជ្ញាស្មារតីជាប់ជានិច្ច ។ កាលបើយើងគ្រប់គ្នាបានអប់រំខ្លួនដោយប្រពៃបែបនេះហើយ ទោះជាពើបប្រទះបញ្ហាវិបត្តធ្ងន់ធ្ងរប៉ុនណា

ក៏យើងនៅតែអាចរិះរកមធ្យោបាយដោះស្រាយបានដែរ ។ អ្នកនិពន្ធទាំងឡាយគប្បីចងចាំជានិច្ចថា អ្នកប្រាជ្ញមិនមែនក្លាយប្រាជ្ញដោយការនិយាយច្រើនឥតប្រយោជន៍ តែដោយការគិតគូរយ៉ាងល្អិតល្អន់ម៉ត់ចត់ គិតហើយ គិតទៀត ថែមទាំងរិះរោរកដំណោះស្រាយដែលនាំមកនូវសារប្រយោជន៍វិជ្ជមាន ចំពោះចំណុចរឿងរ៉ាវនិមួយៗអោយត្រឡប់មករកភាពធូរស្រាយហើយក្សេមក្សាន្ត ។ បើអ្នកនិពន្ធមិនប្រឹងប្រែងត្រិះរិះគិតដោះស្រាយដោយប្រពៃទេ តើអក្សរសិល្ប៍របស់យើងមានតម្លៃមកពីណា ? បើសិនយើងបែរមកពិនិត្យប្រវត្តិអក្សរសិល្ប៍របស់ខ្មែរវិញ កំណាព្យខ្មែរក៏មានច្រើនប្រភេទរាប់មិនអស់ ប៉ុន្តែកំណាព្យខ្លះក៏មានតម្លៃពេញនិយមប្រសើរជាងកំណាព្យដទៃៗឯទៀត ។ ឧទាហរណ៍ កំណាព្យច្បាប់ក្រមង៉ុយ ដែលបច្ចុប្បន្ននេះនៅមានប្រជាប្រិយភាពខ្ពង់ខ្ពស់នៅឡើយ ថ្វីបីកំណាព្យនេះមានអាយុជាងមួយសតវត្សមកហើយក្តី ។ នោះក៏ព្រោះតែច្បាប់ទាំងនោះ បរិបូណ៌ទៅដោយពាក្យពេជន៍ដាស់តឿនស្មារតី គំនិតមាយាទ និងរំលឹកអ្នកអាន អោយមានការពឹងផ្អែកទៅលើខ្លួនឯងជាគោល អោយមានការខ្មាស់អៀនចំពោះអំពើបាប អំពើអបាយមុខ អំពើទុច្ចរិត និងអោយថ្លឹងថ្លែងអំពីអំពើអាក្រក់និងល្អ ថ្លៃថ្នូរឬមិនសមគួរ ជាដើម ។

ឧទាហរណ៍ :  រៀនត្រាប់អ្នកប្រាជ្ញ  បើចង់ឈ្នះកាច  យកស្លូតសង្កត់

ចង់ឈ្នះមនុស្សខឹង  ឲ្យប្រឹងខំអត់  វាជេរវាហត់  វាស្បថលែងខឹង ។

ចង់ឈ្នះអសុរោះ  ស្តីលេងឡេះឡោះ  កុំធ្វើជានឹង

យើងស្តីត្រង់ណា  ឲ្យចំត្រង់ណឹង  ឃើញឬកយើងរឹង  ខ្លាចយើងខាងក្រោយ ។

ចង់ឈ្នះកំណាញ់  ក្រដេក្រដាញ់  សុំអ្វីមិនឲ្យ

បើបានចំណី  ហុចវាញយៗ  តិចដោយច្រើនដោយ  ក្នុងតែវានឹង ។

នេះមន្តព្រះពុទ្ធ  ប្រាជ្ញាឲ្យមុត  ឲ្យគិតថ្លែងថ្លឹង

កុំកាចខុសខ្នាត  កើតខាតឆ្អិតខឹង  កូនអើយខំប្រឹង  កាន់ច្បាប់ទាំងបួន ។

(ដកស្រង់ពី ច្បាប់ល្បើកថ្មី ១ ទំព័រ ៣៧)

នៅក្នុងកំណាព្យដ៏ពិរោះមួយបទ ជាបន្ទាប់តទៅទៀតនេះ ក៏បង្ហាញនូវខ្លឹមសារយ៉ាងទូលំទូលាយ ប្រកបដោយសារៈប្រយោជន៍ផង និងគតិណែនាំក្រើនរំលឹកនូវសតិស្មារតីរបស់អ្នកអាន អោយភ្លឺស្វាង ថែមទៀតផងដែលជាកត្តាបង្ហាញនូវភាពប៉ិនប្រសប់របស់អ្នកនិពន្ធពិតៗ ។ កំណាព្យនេះ មានចំណងជើងថា "ពិចារណ៍" ជាស្នាដៃរបស់អ្នកស្រី កែវ ច័ន្ទបូរណ៍ ដែលមានជាសេចក្តីដូចតទៅនេះ :

មុនគ្រលាស់ពាក្យអសុរស  សូមនឹកដល់អស់ផងមនុស្សគ
មុននឹងទ្រាន់ម្ហូបគ្មានរសល្អ  នឹកអ្នកក្រីក្រខ្វះអាហារ ។
មុននឹងរអ៊ូធុញអ្នកផ្ទះ  សូមគិតអ្នកខ្លះខ្វះគ្រួសារ

មុននឹងចង់ស្លាប់អស់សង្ខារ គិតអ្នកមរណាទាំងក្មេងវ័យ ។
មុននឹងត្អូញត្អែររឿងកូនចៅ នឹកអ្នកឥតផៅកូនប្រុសស្រី
មុនស្អប់ផ្ទះខ្ទមគ្រែឫស្សី នឹកអ្នកដេកដីគ្មានលំនៅ ។
មុនធុញបើកបរចរផ្ទះឆ្ងាយ នឹកអ្នកទាំងឡាយដើរតាមផ្លូវ
ពិបាកហត់នឿយពេលដើរទៅ ទំរាំគោលដៅយ៉ាកយ៉ាងណា ។
មុនចង្អុលចាប់ ទោសផន់គេ មានគិតផងទេទោសអាត្មា
មុនស្អប់ជីវិតសូមពិចារណ៍ តម្លៃសង្ខារដោយសតិ ។

រួមសេចក្ដីមក ការប៉ិនប្រសប់មានតម្លៃឧត្ដុងឧត្ដម្ភ ដែលស្មេរទាំងឡាយគួរប្រឹងប្រែងបណ្ដុះបណ្ដាល គឺការសរសេរសំណេរដែលបង្កើននូវសារៈប្រយោជន៍ដល់ខ្លួននិងសង្គមជាតិ ដែលរក្សាស្មារតីនិងមោទនភាពរបស់ខ្មែរ ហើយដែលមានឥទ្ធិពលញ៉ាំងឲ្យ **ជីវិតជួបពន្លឺរស្មីត្រចះផូរផង់** ដោយការមានស្មារតី មានប្រាជ្ញ អាចដោះស្រាយបញ្ហាដោយសមត្ថភាពរបស់ខ្លួន ។ អ្នកនិពន្ធដែលប៉ិនប្រសប់ គឺជាមនុស្សដែលគិតអ្វីៗតែ ក្នុងផ្លូវល្អ **ផ្លូវសុទន្ធិ មិនទាល់ច្រក ហើយបរិបូរណ៍ទៅដោយក្ដីសង្ឃឹមក្នុងជីវិត** ព្រោះគេមានការ ជឿជាក់លើសមត្ថភាពខ្លួនឯងច្បាស់ថាមានសតិនិងប្រាជ្ញាគ្រប់គ្រាន់ អាចរាវរកមធ្យោបាយសម្រាយបញ្ហា សម្រាលទុក្ខព្រួយក្នុងជីវិត ។ អ្នកនិពន្ធទាំងនោះតែងតែដាស់តឿនខ្លួនគេជានិច្ចផងដែរ ថា "**ខ្លួនជាទីពឹងរបស់ខ្លួន**" នៅគ្រប់កាលៈទេសៈទាំងអស់ ។ សំណេរស្នាដៃដែលផ្ដល់ជាមធ្យោបាយនិងការចេះដឹងប្លែកៗទាំងនោះហើយ ដែលជាមរតកវិសេសវិសាលសំរាប់ខ្មែរជំនាន់ក្រោយ សំរាប់ជួយបណ្ដុះបណ្ដាលសតិប្រាជ្ញ និងទេពកោសល្យដល់អ្នកអានគ្រប់រូប ឲ្យដើរឆ្ពោះទៅរកការចេះដឹង ភាពថ្កុំថ្កើង ភាពភ្លឺស្វាង ចាកផុតអវិជ្ជា និងភាពទាល់ច្រកនានាក្នុងជីវិត អោយសមតាមភាសិតរបស់ព្រះគ្រូសង្ឃរាជជួនណាត ដែលបានដាស់តឿនប្រជាជនខ្មែរជានិច្ចថា "**ប្រាំបួនទាល់ ដប់ទាល់ សូមកុំអោយតែទាល់គំនិតប្រាជ្ញា**" ។ នេះហើយជា**មោទនភាពរបស់អ្នកនិពន្ធ**ពិតប្រាកដ!!!